<u>ទំព័រទី១</u>៖ **ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣៣**

## ដំណើរឆ្លងកាត់អក្សរសិល្ប៍ជប៉ុន

<u>ទំព័រទី២</u>៖

ទស្សនាវដ្ដីលេខ៣៣នេះ និយាយអំពី "**ដំណើរឆ្លងកាត់អក្សរសិល្ប៍ជប៉ុន**"

អក្សរសិល្ប៍មិនមែនគ្រាន់តែជាការអានទេ។ វាក៏ផ្ដល់កន្លែងសម្រាប់ការផ្លាស់ប្ដូរវប្បធម៌ផងដែរ។ អ្នកត្រូវបានអញ្ជើញឱ្យធ្វើដំណើរឆ្លងកាត់រឿងជប៉ុនបុរាណ និងទំនើប ជាមួយនឹងសៀវភៅរឿងដែលអ្នកចូលចិត្តនៅក្នុងដៃរបស់អ្នក។

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំមួយភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្ដី និប៉ុនិកា មានប្រភពមកពីពាក្យ "និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*សារមន្ទីរវប្បធម៌កាដុកាវ៉ា ក្នុងខេត្តសៃតាម៉ា ដែលមានធ្នើរសៀវភៅដូចរោងមហោស្រព ដូចរូបភាពនៅលើគម្រប និងមានការតាំងពិព័រណ៍ផ្សេងៗ* ©Kadokawa Culture Museum

*រូបថតនៅគម្របដោយ៖* RK/@rkrkrk

<u>ទំព័រទី៣</u>៖

*"រឿងនិទានរូបភាពរមូរហ្គេនជិ" (ហ្គេនជិម៉ុណុហ្គាតារីអិម៉ាគិ) តាកិកាវ៉ា វគ្គទី២*

*ការប្រមែប្រមូលដោយ៖ សារមន្ទីរសិល្បៈតុគឹហ្គាវ៉ា* ©The Tokugawa Art Museum Image Archive/DNPartcom

## មាតិកា

- ស្វែងយល់អំពីប្រលោមលោកដែលចំណាស់ជាងគេបំផុតរបស់ពិភពលោក
- ទៅកន្លែងដែល "រឿងនិទានហ្គេនជិ" នៅមានជីវិត
- "នីនង្យ៉ូ ចូរ៉ូរី" រឿងនិទានដែលសម្ដែងដោយល្ខោនអាយ៉ង
- ការទទួលបទពិសោធន៍ជាមួយ លោក មឺរ៉ាកាមិ ហារឹគិ

- ពិភពកំសាន្តនៃសៀវភៅរូបភាព!
- ទស្សនាទីតាំង អានីមេ នៅក្នុងជីវិតពិត
- ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ តួអង្គគំនូរជីវចលនៅតាមផ្លូវនៃប្រទេសជប៉ុន
- រសជាតិជប៉ុន៖ កាស៊ឹតេរ៉ា(នំពងទា)
- ដើរកំសាន្តប្រទេសជប៉ុន៖ ម៉ាត្ស៊ឹយ៉ាម៉ា
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ ប៊ិចកែវ

*ទស្សនាវដ្តីលេខ៣៣* R-041125

*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*

*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*

*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/

<u>ទំព័រទី៤</u>៖

## ស្វែងយល់អំពីប្រលោមលោកដែលចំណាស់ជាងគេបំផុតរបស់ពិភពលោក

នៅសតវត្សរ៍ទី១១ ស្នាដៃអក្សរសិល្ប៍រាជវង្សអូច្ចូ ជារឿងប្រលោមលោកបែបមនោសញ្ចេតនា ដែលនិពន្ធដោយស្ត្រី គឺលោកស្រី មឹរ៉ាសាគិ ស៊ិគិប៊ូ ដែលឱ្យយើងបានស្វែងយល់ពីភាពទាក់ទាញនៃស្នាដៃអក្សរសិល្ប៍បុរាណដែលនៅតែត្រូវបានអានរហូតដល់សព្វថ្ងៃ វាជាឧទាហរណ៍ស្នាដៃដែលរួមបញ្ចូលសោភ័ណភាពជប៉ុន។

ក្យូតុបានរីកចម្រើនជាមជ្ឈមណ្ឌលនយោបាយ និងវប្បធម៌ ឈានដល់កម្រិតកំពូលក្នុងកំឡុងសម័យហេអាន (៧៩៤-១១៨៥)។ នៅពេលដែលសង្គមអភិជនបានចាក់ឫសហើយ វប្បធម៌រាជវង្សអូច្ចូដ៏ឆើតឆាយពិសេសរបស់ប្រទេសជប៉ុនបានរីកដុះដាលឡើង។

រឿងនិទានហ្គេនជិ គឺជាប្រលោមលោកចំណាស់ជាងគេបំផុតរបស់ពិភពលោកដែលនិពន្ធដោយ លោកស្រី មឹរ៉ាសាគិ ស៊ិគិប៊ូ នៅដើមសតវត្សរ៍ទី១១ នៅពេលដែលវាស្ថិតនៅកម្រិតកំពូលនៃយុគមាស។ រឿងនេះផ្តោតទៅលើជីវិតរបស់ព្រះអង្គម្ចាស់ហ៊ីការុ ហ្គេនជិ ដោយពណ៌នាអំពីជីវិតរស់រវើករបស់ទ្រង់ នៅពេលមានស្នេហាជាមួយស្ត្រីជាច្រើនជាបន្តបន្ទាប់ និងបានឡើងកាន់អំណាចនៅក្នុងសង្គមអភិជន ប៉ុន្តែចុងក្រោយ ទ្រង់រស់នៅដោយភាពខកចិត្ត។

រឿងនេះ មាន៥៤ភាគ មានតួអង្គច្រើនជាង៥០០តួ ហើយមានរយៈពេល៧០ឆ្នាំ នៅក្នុងពិភពប្រតិដ្ឋនេះ។ សាច់រឿងបានបង្ហាញយ៉ាងឥតខ្ចោះអំពីដំណើរជីវិតនៅក្នុងព្រះបរមរាជវាំង ក្នុងមាត្រដ្ឋានដ៏អស្ចារ្យ។ ប្រលោមលោកនេះបានទាក់ទាញមនុស្សជាច្រើន ហើយត្រូវបានបកប្រែ៩០ភាសា ដោយចាប់ផ្តើមដោយការបកប្រែជាភាសាអង់គ្លេសដោយអ្នកអក្សរសិល្ប៍អង់គ្លេស។

<u>ទំព័រទី៥៖</u>

លើសពីនេះទៀត "រឿងនិទានហ្គេនជិ" ក៏បានបំផុសគំនិតផលិតស្នាដៃជាច្រើនគ្រប់វ័យ។ គំនូរដែលល្បីជាងគេគឺគំនូរហ្គេនជិ"ហ្គេនជិអិ" ។ តាំងពីសម័យហេអាន រហូតមកដល់បច្ចុប្បន្ន ស្នាដៃជាច្រើនត្រូវបានផលិតឡើង ដើម្បីបង្កើតឡើងវិញនូវពិភពរឿងប្រតិដ្ឋដោយស្នាដៃផ្ទាល់ខ្លួនរបស់ពួកគេ ហើយឥឡូវនេះវាបានក្លាយជាជ្រុងមួយនៃសិល្បៈជប៉ុន។ រឿងប្រលោមលោក ក៏បានជះឥទ្ធិពលយ៉ាងខ្លាំងលើសិល្បៈសម្តែងជាបន្តបន្ទាប់ដូចជា ពិធីមាគ៌ានៃក្លិនក្រអូប(កូដូ) ពិធីលៀងតែ(សាដូ) ល្ខោនណូ និងល្ខោនកាប៊ូគិ ហើយឥឡូវនេះវាថែមទាំងត្រូវបានពណ៌នាក្នុងរឿងអានិមេ(គំនូរជីវចល) និងម៉ានហ្គា(សៀវភៅតុក្កតា) ទៀតផង។ វាមិនមែនជាការបំផ្លើសទេ ដែលនិយាយថា "រឿងនិទានហ្គេនជិ" បានត្រួសត្រាយសិល្បៈប្រភេទចម្រុះ ដែលជប៉ុនពូកែក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ។

តាមរយៈការទៅទស្សនាកន្លែងនានាក្នុងទីក្រុងក្យូតូ និងកន្លែងផ្សេងៗទៀតដែលទាក់ទងនឹងរឿង ឬទស្សនាគំនូរហ្គេនជិអិ និងស្នាដៃសិល្បៈផ្សេងទៀតដោយផ្ទាល់ វានឹងកាន់តែងាយស្រួលក្នុងការស្រមៃមើលពិភពលោកដែលបង្ហាញនៅក្នុង"រឿងនិទានហ្គេនជិ" ។ រឿងប្រលោមលោក គឺជាមគ្គុទ្ទេសក៍ដ៏អស្ចារ្យសម្រាប់ការស្វែងយល់ពីព្រលឹងនៃវប្បធម៌ជប៉ុន ដោយគិតអំពីរាជវង្សអូចូ ជាង១,០០០ឆ្នាំមុន។

*រូបខាងលើ៖ រឿងនិទានហ្គេនជិវ៉ាកាណា (ផ្ទាំងគំនូរបត់) គូរដោយវិចិត្រករ តុសា មិត្សឹអុគិ នៅសតវត្សរ៍ទី១៧*

(*ការប្រមែប្រមូល៖ វិចិត្រសាលសិល្បៈហ្វ្រេវ័* (Freer Gallery of Art), *អំណោយពី* Charles Lang Freer)

*រូបខាងស្តាំនៅកំពូល៖ កម្រងរឿងនិទានហ្គេនជិសរសេរដោយដៃ នៅសតវត្សរ៍ទី១៣*

(*ការប្រមែប្រមូល៖ បណ្ណាល័យហូសា ទីក្រុងណាហ្គូយ៉ា*)

*រូបនៅកណ្តាល៖ រឿងនិទានហ្គេនជិ បកប្រែជាភាសាអង់គ្លេស ដោយ*Arthur Waley

*រូបខាងស្តាំផ្នែកក្រោម៖ គំនូរនៃរឿងនិទានហ្គេនជិ អ្នកនិពន្ធ លោកស្រី មឹរ៉ាសាគិ ស៊ិគិប៊ូ ចាប់ពីសតវត្សរ៍ទី១៩*

(*ការប្រមែប្រមូល៖ សារមន្ទីរជាតិតូក្យូ*)

ទំព័រទី៦៖

## នៅកន្លែងដែល "រឿងនិទានហ្គេនជិ" នៅមានជីវិត

**ព្រះបរមរាជវាំងចាស់ ដែលបានក្លាយជាឆាកសម្តែងរឿង**

✧ ព្រះបរមរាជវាំងក្យូតុ

ឈុតឆាកភាគច្រើននៃរឿងនិទានហ្គេនជិបានកើតឡើងនៅក្យូតុ។ ទីតាំងជាច្រើនដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយប្រលោមលោកនៅតែមានដល់សព្វថ្ងៃនេះ ហើយកន្លែងដែលសំខាន់បំផុតនោះគឺ ព្រះបរមរាជវាំងក្យូតុ។

ព្រះបរមរាជវាំងបុរាណនេះ ជាកន្លែងដែលព្រះចៅអធិរាជជប៉ុនបានគង់នៅរហូតដល់រាជធានីត្រូវបានផ្លាស់ទៅទីក្រុងតូក្យូក្នុងសតវត្សរ៍ទី១៩។ ព្រះបរមរាជវាំងបុរាណនេះ គឺជាកន្លែងកំណើតរបស់តួអង្គហ៊ីការុ ហ្គេនជិ និងឈុតឆាករឿងជាច្រើនបានកើតឡើងនៅក្នុងប្រលោមលោក។ ថ្វីត្បិតតែព្រះបរមរាជវាំងក្យូតុបច្ចុប្បន្នត្រូវបានសាងសង់ឡើងវិញក៏ដោយ ប៉ុន្តែស្ថាបត្យកម្មរបស់វា នៅតែធ្វើតាមរចនាបថសម័យហេអានយ៉ាងត្រឹមត្រូវ ដើម្បីរក្សាបាននូវបរិយាកាសដ៏មានន័យនៅសម័យនោះ។ មិនមានកន្លែងណាល្អជាងនេះ ដើម្បីទទួលយកបទពិសោធន៍នៃបរិយាកាសនៃរឿងនិទានហ្គេនជិដោយផ្ទាល់នោះទេ។

*រូបខាងឆ្វេងផ្នែកលើ៖ ស៊ីនស៊ីនដេន ជាកន្លែងដែលពិធីជាច្រើនត្រូវបានប្រារព្ធឡើង*

*រូបខាងស្តាំ៖ បល្ល័ង្ករបស់អធិរាជហៅថា តាកាមិគឺរ៉ា*

*(រូបថតផ្តល់សិទ្ធិដោយ ទីភ្នាក់ងារគ្រួសារអធិរាជ)*

**ទិដ្ឋភាពដ៏អស្ចារ្យនៃក្បួនដង្ហែដែលស្លៀកសម្លៀកបំពាក់រាជវង្សបុរាណ**

✧ ពិធីបុណ្យអាអុអិ

នៅដើមខែឧសភា ពិធីបុណ្យអាអុអិ គឺជាពិធីបុណ្យដ៏សំខាន់មួយតំណាងឱ្យទីក្រុងក្យូតុដែលត្រូវបានរំលេចដោយក្បួនដង្ហែដែលមានមនុស្សជាង៥០០នាក់ស្លៀកពាក់សំលៀកបំពាក់រាជវង្សពីសម័យហេអានបានដង្ហែតាមដងផ្លូវក្នុងទីក្រុង។ ឈ្មោះផ្លូវការនៃពិធីបុណ្យនេះ គឺពិធីបុណ្យកាម៉ុ។ វាត្រូវបានគេជឿថា បានអនុវត្តជាង១៤០០ឆ្នាំមុន និងត្រូវបានលេចឡើងនៅក្នុងវគ្គ"អាអុអិ" នៃរឿងនិទានហ្គេនជិ។

*រូបខាងស្តាំ៖ ក្បួនដង្ហែនៃពិធីបុណ្យនេះត្រូវបានគេហៅថា "រ៉ុតុ ណុ ហ៊្គិ"*

<u>ទំព័រទី៧</u>៖

**រីករាយជាមួយពិភពរឿងនិទានហ្គេនជិ 3D**

✧ រឿងនិទានហ្គេនជិ នៅសារមន្ទីរទីក្រុងអ៊ុជិ

សារមន្ទីរនេះត្រូវបានរៀបចំឡើងបន្ទាប់ពីរឿងនិទានហ្គេនជិមានទីតាំងនៅទីក្រុងអ៊ុជិ ក្នុងខេត្តក្យូតុ ដែលជាកន្លែងសំខាន់នៃវគ្គចុងក្រោយរបស់ប្រលោមលោក ដែលជាទូទៅគេហៅថា "អ៊ុជិ ជូចូ" ឬ "វគ្គទី១០នៃអ៊ុជិ"។ សារមន្ទីរអ៊ុជិជាសារមន្ទីរតែមួយគត់ ដែលផ្តល់ឱ្យអ្នកទស្សនានូវឱកាសដើម្បីស្វែងយល់ដោយផ្ទាល់អំពីពិភពនៃរឿងនិទានហ្គេនជិ តាមរយៈការដាក់តាំងបង្ហាញដោយរៀបរាប់លម្អិតអំពីជីវិតក្នុងព្រះបរមរាជវាំង និងសម្លៀកបំពាក់អ្នកអភិជនក្នុងសម័យនោះ។

*រូបខាងលើ៖ ការតាំងពិព័រណ៍បង្កើតឡើងវិញនូវឈុតឆាកពីរឿងនិទានហ្គេនជិ ដែលស្ត្រីនៃគ្រួសារអភិជនលេងហ្គុ(ល្បែងអុកប្រពៃណីជប៉ុន)។*

*រូបខាងស្តាំ៖ រទេះគោនៅសម័យហេអាន (ធ្វើឡើងវិញ) ដែលប្រើសម្រាប់ជាយានជំនិះរបស់ពួកអភិជននៅពេលនោះ។*

**ព្រះវិហារដែលទាក់ទងនឹងលោកស្រី មឺរ៉ាសាគិ ស៊ិគិប៊ូ**

✧ ព្រះវិហារអ៊ិស៊ិយ៉ាម៉ា

ព្រះវិហារនេះត្រូវបានសាងសង់ឡើងក្នុងសតវត្សរ៍ទី៨ ហើយមានទីតាំងនៅទីក្រុងអុត្ស៊ឺ ខេត្តស៊ីហ្គា។ ព្រះវិហារអ៊ិស៊ិយ៉ាម៉ា គឺជាកន្លែងដែលត្រូវបានគេនិយាយថា លោកស្រី មឺរ៉ាសាគិ ស៊ិគិប៊ូ យុំខ្លួនឯងដើម្បីគិតពី"រឿងនិទានហ្គេនជិ" ។ នៅក្នុងសាលធំនៅតែមានបន្ទប់ "ហ្គេនជិ ណុ ម៉ា" រហូតដល់សព្វថ្ងៃ ដែលវាត្រូវបានគេនិយាយថាជាបន្ទប់ដែលលោកស្រី មឺរ៉ាសាគិ ស៊ិគិប៊ូ បានសរសេររឿង។ "ពិព័រណ៍ព្រះវិហារអ៊ិស៊ិយ៉ាម៉ា និងមឺរ៉ាសាគិ ស៊ិគិប៊ូ" ដែលប្រារព្ធឡើងជារៀងរាល់និទាឃរដូវ និងរដូវស្លឹកឈើជ្រុះ បានដាក់តាំងបង្ហាញសម្ភារៈទាក់ទងនឹង "រឿងនិទានហ្គេនជិ"។

*រូបខាងឆ្វេង៖ ព្រះវិហារអ៊ិស៊ិយ៉ាម៉ា គឺជាកន្លែងដ៏ល្បីល្បាញសម្រាប់មើលព្រះចន្ទ។ វាក៏បានបំផុសគំនិត លោកស្រីមឺរ៉ាសាគិ ស៊ិគិប៊ូ សម្រាប់ "រឿងនិទានហ្គេនជិ" នៅពេលដែលលោកស្រីបានឃើញព្រះចន្ទឆ្លុះចាំងលើផ្ទៃបឹង។*

*រូបខាងស្តាំ៖ រូបសំណាកសំរិទ្ធរបស់លោកស្រីមឺរ៉ាសាគិ ស៊ិគិប៊ូ នៅក្នុងបរិវេណព្រះវិហារ*

(*រូបថតផ្តល់សិទ្ធិដោយ ព្រះវិហារអ៊ិស៊ិយ៉ាម៉ា*)

**ទស្សនាគំនូរហ្គេនជិ(ហ្គេនជិអិ) ដើម**

✧ សារមន្ទីរសិល្បៈតុគឹហ្គាវ៉ា

សារមន្ទីរសិល្បៈនេះស្ថិតនៅទីក្រុងណាហ្គូយ៉ា ខេត្តអៃឈិ គឺជាផ្ទះរបស់រឿងនិទានរូបភាពរមូរហ្គេនជិ ("ហ្គេនជិម៉ុណុហ្គាតារីអិម៉ាគិ") ដែលត្រូវបានបង្កើតឡើងនៅដើមពាក់កណ្តាលសតវត្សរ៍ទី១២។ រឿងនិទានរូបភាពរមូរត្រូវបានបញ្ជូនបន្តពីមួយជំនាន់ទៅមួយជំនាន់ក្នុងគ្រួសារអុវ៉ារិ តុគឹហ្គាវ៉ា ហើយត្រូវបានដាក់តាំងបង្ហាញនៅសារមន្ទីរនេះជារៀងរាល់ឆ្នាំក្នុងខែវិច្ឆិកា ព្រមទាំងមានការតាំងពិព័រណ៍គ្រឿងសង្ហារិមក្នុងពិធីមង្គលការដ៏ប្រណិតដែលបំផុសគំនិតពីរឿងនិទានហ្គេនជិផងដែរ។

*រូបខាងក្រោម៖ សារមន្ទីរដែលមានស្នាដៃសិល្បៈ ១០,០០០រូប បានពីគ្រួសារអុវ៉ារិ តុគឹហ្គាវ៉ា ដែលជាស្តេចត្រាញ់ដ៏មានឥទ្ធិពលនៅសម័យអេដូ។ (រូបថតផ្តល់សិទ្ធដោយសារមន្ទីរសិល្បៈតុគឹហ្គាវ៉ា)*

*រូបខាងលើ៖ រឿងនិទានរូបភាពរមូរហ្គេនជិ ("ហ្គេនជិម៉ុណុហ្គាតារីអិម៉ាគិ") តាកិកាវ៉ា វគ្គទី២ (រូបភាពច្បាស់សូមមើលទំព័រ២–៣នៅក្នុងទស្សនាវដ្តីនេះ។)*

<u>ទំព័រទី៨</u>៖

## "នីនង្យ៉ូ ចូរូរី" រឿងនិទានដែលសម្តែងដោយល្ខោនអាយ៉ង

និនង្យ៉ូ ចូរូរី គឺជាសិល្បៈសម្តែងបែបប្រពៃណីដ៏សំខាន់មួយក្នុងចំណោមសិល្បៈសំខាន់ទាំង៣របស់ប្រទេសជប៉ុនរួមជាមួយនឹងល្ខោនណូ និងល្ខោនកាប៊ូគិ។ សិល្បៈនៃការបង្ហាញរឿងតាមរយៈអាយ៉ងបានកើតឡើងក្នុងសម័យអេដូ(១៦០៣-១៨៦៨) ហើយបានបន្តរហូតដល់បច្ចុប្បន្ន។

*រូបថតដោយគឺរិហារ៉ា អុសាមុ*

នៅក្នុងល្ខោនអាយ៉ងប្រភេទនេះ អ្នកសម្តែងម្នាក់ហៅថា តាយូ ជាអ្នកនិទានរឿង ឬ អ្នកពោល ហើយស្យ៉ាមិសេនដែលជាឧបករណ៍តន្ត្រីខ្សែ បានបន្ថែមឈុតឆាកដោយសំឡេង និងអាយ៉ងធ្វើចលនាយ៉ាងរស់រវើក។ នីនង្យ៉ូ ចូរូរី គឺជាសិល្បៈសម្តែងរួមគ្នារបស់ជប៉ុនតែមួយគត់ ដែលអ្នកសម្តែងបីនាក់ធ្វើការរួមគ្នាយ៉ាងល្អឥតខ្ចោះ ដើម្បីនិទានរឿង។

ដើមកំណើតនៃការសម្តែងរឿងអាយ៉ងទាំងនេះស្ថិតនៅជាមួយ"កាតារិម៉ុណុ(ការនិទានរឿង)" ដែលជាការនិទានតាមតន្ត្រី។ ដំបូងឡើយលេងដោយ ប៊ីវ៉ា (ឧបករណ៍តន្ត្រីខ្សែ ស្រដៀងពិណា ឬ ចាប៉ី) និងសំឡេងផ្លិតបិទបើក ប៉ុន្តែនៅសតវត្សរ៍ទី១៦ ចូរូរី ត្រូវបានបង្កើតឡើងជាមួយនឹងស្យ៉ាមិសេន(ឧបករណ៍តន្ត្រីខ្សែ ស្រដៀងចាប៉ី)។ បន្ទាប់មក

វាបានបញ្ចូលគ្នាជាមួយល្ខោនអាយ៉ងក្នុងសតវត្សរ៍ទី១៧ នៅអូសាកា បង្កើតបានជា "នីនង្យ៉ូ ចូរូរី"។ នៅពេលគិតអំពីល្ខោនអាយ៉ង ប្រហែលជាស្រមៃដល់រឿងនិទានសម្រាប់ក្មេងៗ ប៉ុន្តែល្ខោនអាយ៉ង នីនង្យ៉ូ ចូរូរី គឺសម្តែងដោយផ្អែកលើរឿងនិទានប្រវត្តិសាស្ត្រ រឿងរ៉ាវឧបទ្ទវហេតុណាមួយ ឬ ស្នេហារវាងបុរស និងស្ត្រី ស្នេហារវាងឪពុកម្តាយ និងកូន ដែលមនុស្សពេញវ័យអាចរីករាយទស្សនាបាន ដូចជារឿង"សុណិហ្សាគិ ស៊ីនជូ(ស្នេហាអត្តឃាតនៅសុណិហ្សាគិ" និពន្ធដោយ លោក ឈិកាម៉ាត្ស៊ូ ម៉ុនហ្សាអិម៉ុន ដែលសម្តែងជាលើកដំបូងក្នុងឆ្នាំ១៧០៣ ហើយនៅតែពេញនិយមរហូតដល់ពេលបច្ចុប្បន្ននេះ។

នីនង្យ៉ូ ចូរូរី នៅទីបំផុតបានរីកសាយពីស្រុកកំណើតរបស់ខ្លួននៅអូសាកា ទៅកាន់ទីក្រុងក្នុងតំបន់នៅទូទាំងប្រទេសជប៉ុន។ នៅខេត្តតុគឺស៊ីម៉ា ស្ថិតក្នុងតំបន់ស៊ីកុគឺប្រទេសជប៉ុន មានរោងល្ខោនអាយ៉ងជាច្រើនត្រូវបានបង្កើតឡើងតាំងពីសម័យអេដូ ហើយមានការសម្តែងនីនង្យ៉ូ ចូរូរីនៅរោងខាងក្រៅ ក្នុងបរិវេណព្រះវិហារ សម្រាប់ការសម្តែងជាសាធារណៈ បានធ្វើឱ្យនីនង្យ៉ូ ចូរូរីរីកចម្រើន។ សូម្បីតែសព្វថ្ងៃនេះមានរោងល្ខោនអាយ៉ងជាង២០ នៅតែមានការសម្តែង ដូចជារោងល្ខោនអាវ៉ារ៉ូបិអិយ៉ាស៊ិគិ ក្នុងទីក្រុងតុគឺស៊ីម៉ាមានការសម្តែងសឹងតែរាល់ថ្ងៃ។

<u>ទំព័រទី៩៖</u>

រឿងដែលសម្តែងជាញឹកញាប់បំផុតនៅរោងល្ខោននេះគឺផ្អែកលើបញ្ហាគ្រួសារដែលកើតឡើងនៅក្នុងតំបន់ ហើយបង្ហាញពីសេចក្តីស្រឡាញ់យ៉ាងរំជើបរំជួលរវាងឪពុកម្តាយ និងកូន។ នៅក្នុងឈុតមួយ នៅពេលដែលម្តាយ និងកូនបានជួបជុំគ្នាឡើងវិញ ស្នាអាយ៉ងតួម្តាយរាងញ័របន្តិច ហើយនាងបានលើកដៃរបស់នាងថ្នមៗទៅកាន់មុខដែលឱនចុះ ដែលកាយវិការអាយ៉ងនោះហាក់ដូចជាកំពុងស្រក់ទឹកភ្នែកពិតៗ។ អ្វីដែលធ្វើឱ្យការបង្ហាញចេញបានជាក់ស្តែងបែបនេះ គឺជាវិធីសាស្ត្រតែមួយគត់ ដែលមិនអាចប្រៀបផ្ទឹមបាននៅទីកន្លែងណាផ្សេងទេក្នុងពិភពលោកនេះ ក្នុងការរៀបចំតួអាយ៉ងមួយដោយមនុស្សបីនាក់។ តាមរយៈការចែករំលែកតួនាទីនៃចលនាផ្នែកផ្សេងៗគ្នានៃអាយ៉ង គឺក្បាល ដៃស្តាំ ដៃឆ្វេង និងជើង ដើម្បីសម្រេចបាននូវចលនារលូនដូចមនុស្ស ជាមួយនឹងកាយវិការ និងអារម្មណ៍លម្អិតយ៉ាងសម្បូរបែប។ សំឡេងនៃការនិទានដោយតាយូ(អ្នកពោល) និងសំឡេងស្រទន់នៃស្យាមិសេន បន្ថែមនូវភាពប្លែកភ្នែកថែមទៀត។ សំឡេង(និទានរឿង) សំឡេង(ស្យាមិសេន) និងចលនារបស់អាយ៉ងរួមគ្នា បង្កើតបាននូវពិភពអាយ៉ងដ៏ប្រណិត។

អ្នកអាចស្វែងរកការសម្តែងអាយ៉ងនីនង្យ៉ូ ចូរូរី ទាំងនៅក្នុងខេត្តតុគឺស៊ីម៉ា និងនៅទូទាំងប្រទេសជប៉ុន។ យើងចង់ឱ្យអ្នករីករាយជាមួយរឿងដែលពណ៌នាពីជីវិតដែលនៅក្នុងចិត្តដ៏សម្បូរបែបរបស់ប្រជាជនយ៉ាងលម្អិតតាមរយៈល្ខោនអាយ៉ង។

*១. ឈុតម្តាយ និងកូនបានជួបជុំគ្នានៅក្នុងរឿង "គេសេអាវ៉ាណុណារីតុ ជូនរេកាដាន"។*

*២. អ្នកសម្ដែងដែលធ្វើចលនាតួអាយ៉ងឡើងលើឆាកក្នុងឈុតសម្លៀកបំពាក់ពណ៌ខ្មៅ និងក្រណាត់ខ្មៅ ដើម្បីកុំឱ្យលាយឡំជាមួយផ្ទៃខាងក្រោយនៅលើឆាក។*

*៣. តាយូ (អ្នកនិទានរឿង ឬ អ្នកពោល) និងអ្នកលេងស្យាមិសេន សម្ដែងនៅលើយឹកា(ឥដ្ឋ)ក្បែរឆាក។*

*៤. ចំណងជើងរងត្រូវបានបង្ហាញជាភាសាជប៉ុន និងអង់គ្លេស នៅផ្នែកខាងលើនៃឆាកនៅរោងល្ខោនអាវ៉ាជូរ៉ូបិអិយ៉ាសិុគិ។*

*៥. សម្ភារៈដែលទាក់ទងនឹងល្ខោននីនង្យ៉ូ ចូរូរី ត្រូវបានដាក់តាំងបង្ហាញនៅរោងល្ខោនអាវ៉ាជូរ៉ូបិអិយ៉ាសិុគិ។*

*៦. វេទិកាសហគមន៍ជនបទ នៅបរិវេណព្រះវិហារក្នុងខេត្តតុគឹស៊ីម៉ា។ អ្នកស្រុកប្រមូលផ្តុំគ្នាម្តងក្នុងមួយឆ្នាំសម្រាប់ការសម្ដែងសាធារណៈ។*

<u>ទំព័រទី១០៖</u>

## ការទទួលបទពិសោធន៍ជាមួយ លោក មឹរ៉ាកាមិ  ហារឹគិ

លោកមឹរ៉ាកាមិ ហារឹគិ ជាអ្នកនិពន្ធរឿងប្រលោមលោក ដែលមានអ្នកគាំទ្រទូទាំងពិភពលោក ហើយបណ្ណាល័យមឹរ៉ាកាមិ ហារឹគិ បានបើកនៅទីក្រុងតូក្យូ។ ចាប់ពីស្ថាបត្យកម្ម គ្រឿងសង្ហារិម រហូតដល់ធ្នើរសៀវភៅ ជាកន្លែងដែលនឹងធ្វើឱ្យអ្នកឈ្លក់វង្វេងជាមួយនឹងការប្រមូលផ្តុំដ៏ល្អបំផុតនៃអក្សរសិល្ប៍របស់លោកមឹរ៉ាកាមិ។

*រូបថត៖ គីរីហារ៉ា អុសាមឺ,* CHUOKORON–SHINSHA, INC.

ក្នុងអាជីពជាអ្នកនិពន្ធអស់រយៈពេល៤០ឆ្នាំ លោក មឹរ៉ាកាមិ ហារឹគិ បានផលិតស្នាដៃជាច្រើនដូចជារឿងហ៊ីត៊ីជិ អុម៉ិហ្គីរីបូកេន(ដំណើរផ្សងព្រេងជាមួយសត្វចៀម) រឿងណុរឺវេ ណុ ម៉ុរី (ព្រៃន័រវេស) និងរឿង1Q84 (អ៊ីកគ្យូហាឈិយូយ៉ុន)ជាដើម។ ប្រលោមលោករបស់លោកត្រូវបានបកប្រែជាង៥០ភាសា។ អ្នកគាំទ្រជុំវិញពិភពលោកចាប់អារម្មណ៍នឹងសាច់រឿងដែលមានលក្ខណៈពិសេសប្លែក ស៊ីជម្រៅ ប៉ុន្តែងាយស្រួលក្នុងការអាន។

នៅខែតុលា ឆ្នាំ២០២១ កន្លែងដែលធ្វើឱ្យមានអារម្មណ៍នៅជិតលោកមឹរ៉ាកាមិ គឺបណ្ណាល័យអក្សរសិល្ប៍អន្តរជាតិ (បណ្ណាល័យមឹរ៉ាកាមិ ហារឹគិ) បានបើកនៅសាកលវិទ្យាល័យវ៉ាសិដា ក្នុងទីក្រុងតូក្យូ ដែលធ្លាប់ស្គាល់ថាជាសាកលវិទ្យាល័យដែលលោកបានសិក្សា។ នៅពេលអ្នកដើរចូលទៅតាមមាត់ច្រកចូល អ្នកនឹងឃើញ "កៃដានហុនដាណា (ជណ្តើរធ្នើរសៀវភៅ)" ដែលមានធ្នើរសៀវភៅតម្រង់ជួរនៅខាងឆ្វេង និងខាងស្តាំនៃលំហាពិដានយ៉ាងខ្ពស់។ លំហាដែលបង្កើតឡើងដោយស្ថាបត្យករ គឺម៉ា កេនហ្គោ ដែលមើលឃើញស្នាដៃរបស់លោកមឹរ៉ាកាមិថាជា "ផ្លូវរូងក្រោមដីដែលភ្ជាប់ការពិត និងការប្រតិដ្ឋ" ហើយបានរចនាលំហានោះ ដើម្បីធ្វើឱ្យអ្នកទស្សនាមានអារម្មណ៍ថា ដូចជាអ្នកបានឈានជើងចូលទៅក្នុងពិភពនៃស្នាដៃរបស់លោកមឹរ៉ាកាមិ។

នៅពេលអ្នកចុះទៅបន្ទប់ក្រោមដី អ្នកនឹងឃើញទិដ្ឋភាពនៃការសិក្សារបស់លោកមឹរ៉ាកាមិ ជាមួយនឹង តុ និងកៅអីដែលត្រូវបានផលិតឡើងវិញយ៉ាងលម្អិត រួមទាំងទំហំធ្នើរ និងសូម្បីតែខ្មៅដៃដែលលោកស្រលាញ់ក៏ត្រូវបានផលិតឡើងវិញដែរ។ ការចម្លងបរិយាកាសនៃកន្លែងដែលលោកមឹរ៉ាកាមិបានបង្កើតស្នាដៃរបស់លោក គឺជាកន្លែងដ៏ល្អមួយ សម្រាប់ការបំផុសគំនិតថ្មីៗ។

<u>ទំព័រទី១១៖</u>

ជាន់ទីមួយនៃបណ្ណាល័យ គឺពោរពេញទៅដោយស្នាដៃបោះពុម្ពដំបូងដ៏កម្រ និងការបកប្រែស្នាដៃរបស់លោកមឹរ៉ាកាមិជាភាសាផ្សេងៗគ្នាជាច្រើន។ កន្លែងអានមាននៅគ្រប់ទីកន្លែង ដូច្នេះអ្នកទស្សនាអាចជ្រើសយកសៀវភៅដែលអ្នកពេញចិត្ត ហើយអាចអង្គុយនៅកន្លែងដែលមានផាសុកភាព កន្លែងណាក៏បានដើម្បីអាន ប៉ុន្តែយើងសូមណែនាំបន្ទប់សំឡេង ដែលជាកន្លែងដ៏ល្អមួយទៀតសម្រាប់អង្គុយអានសៀវភៅ។ លោកមឹរ៉ាកាមិ ជាអ្នកស្នេហាចង្វាក់ហ្សាស(jazz) ហើយបាននិយាយជាសាធារណៈជាច្រើនដងអំពីឥទ្ធិពលតន្ត្រីនេះមានមកលើការសរសេររបស់លោក។ លោកថែមទាំងបានបើកបារចង្វាក់ហ្សាសមួយមានឈ្មោះថា "ផេធើខេត (peter-cat)" ។ ប្រសិនបើអ្នកបានអានប្រលោមលោករបស់លោកមឹរ៉ាកាមិបណ្តើរ ស្តាប់កំណត់ត្រាដែលប្រមូលបានដោយលោកមឹរ៉ាកាមិជាមួយនឹងឈុតសំឡេងបណ្តើរ នោះអ្នកកំពុងចំណាយពេលមួយដ៏ពិសេសហើយ។

លើសពីនេះ មានហាងកាហ្វេដែលដំណើរការដោយនិស្សិត និងបន្ទប់ពិសោធន៍ ដែលអាចប្រើប្រាស់សម្រាប់ការប្រជុំស្រាវជ្រាវ និងព្រឹត្តិការណ៍នានាផងដែរ។ បណ្ណាល័យនេះឆ្លុះបញ្ចាំងពីបំណងប្រាថ្នារបស់លោក មឹរ៉ាកាមិ ក្នុងការជម្រុញកន្លែងសម្រាប់ភ្ជាប់ទំនាក់ទំនងរបស់មនុស្ស ជាជាងគ្រាន់តែជាបណ្ណសារ។ ទីនេះបានផ្តល់នូវកន្លែងសុខស្រួលសម្រាប់មនុស្សគ្រប់គ្នា ដើម្បីជ្រមុជខ្លួនទៅក្នុងបរិយាកាសនៃពិភពលោករបស់លោកមឹរ៉ាកាមិ និងរីករាយជជែកអំពីភាពទាក់ទាញនៃអក្សរសិល្ប៍។

**លោក មឹរ៉ាកាមិ ហារឹគិ៖**

**ខ្ញុំគិតថារឿងនិទាន គឺជាភាសាសកល។ ហើយរឿងនិទានក៏ជាខ្លឹមសារនៃប្រលោមលោកផងដែរ។ ដូច្នេះ តាមរយៈប្រលោមលោក យើងគួរតែអាចនិយាយជាមួយមនុស្សជាច្រើនជុំវិញពិភពលោក ហើយយល់គ្នាទៅវិញទៅមក។ យើងបានគ្រោងរៀបចំបណ្ណាល័យអក្សរសិល្ប៍អន្តរជាតិរ៉ាសិដានេះ ជាមួយនឹងគំនិតដែលគិតថា វានឹងអាចក្លាយជាមជ្ឈមណ្ឌលមួយនៃចលនាបែបនេះ។ ខ្ញុំសង្ឃឹមថាមនុស្សជាច្រើននឹងអាចប្រើវាដោយសេរី។**

*១. ជណ្តើរនៃធ្នើរសៀវភៅចុះមកបន្ទប់ក្រោមដី។ វាសាងសង់ឡើងដើម្បីអោយអ្នកអានអាចអង្គុយចុះ ហើយអានបាន។*

*២. ច្រកចូលបណ្ណាល័យគ្របដណ្តប់ដោយខ្លោងឈើដ៏កក់ក្តៅ។*

*៣. បណ្ណាល័យមានសៀវភៅបកប្រែជាង៥០ភាសាផ្សេងៗគ្នា។*

*៤. បន្ទប់សិក្សាដែលត្រូវបានបង្កើតឡើងវិញស្ទើរតែដូចនឹងរបស់ពិតៗរបស់លោកមីវ៉ាកាមិ មានដូចជាតុ សាឡុង និងសម្ភារៈផ្សេងៗ។*

*៥. បន្ទប់សំឡេងជាមួយកំណាត់ត្រាដែលលោកមីវ៉ាកាមិប្រមូលបានជាច្រើនឆ្នាំ។*

*៦. រូបគំនូរគូរដោយលោកមីវ៉ាកាមិ ហារីគិ អំពីបុរសចៀមដែលបង្ហាញនៅក្នុងរឿង "ហ៊ីត្ស៊ីជិ អុ មិហ្គុរី បូកេន (ដំណើរផ្សងព្រេងនៃសត្វចៀម)" ។ គំនូរនេះគូរនៅលើជញ្ជាំងនៃសាលវិចិត្រសាលកន្លែងអង្គុយលេង(Gallery Lounge)។*

*៧. ឈុតនៅក្នុងរឿង"ដ្រាយ ម៉ាយ ខារ* (Drive My Car) *បើកឡានរបស់ខ្ញុំ" នៅឆ្នាំ២០២១។*

©2021 Drive My Car Production Committee (*រក្សាសិទ្ធដោយគណកម្មការផលិតរឿងដ្រាយម៉ាយខារ ២០២១*)

<u>ទំព័រទី១២៖</u>

## ពិភពកំសាន្តនៃសៀវភៅរូបភាព!

ប្រជាជនជប៉ុនចូលចិត្តសៀវភៅរូបភាព។ ទាំងកុមារ និងមនុស្សពេញវ័យមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះស្នាដៃដែលបង្ហាញពីប្រធានបទប្លែកៗ ជាមួយនឹងប្រយោគងាយយល់ និងរូបភាពកំប្លែង។ ទីក្រុងធំៗក្នុងប្រទេសជប៉ុនសម្បូរទៅដោយហាងឯកទេសដែលផ្តល់ជូននូវផលិតផលជាច្រើនប្រភេទដោយផ្តោតទៅលើសៀវភៅរូបភាពពេញនិយម។ តោះស្វែងយល់ពីពិភពចម្រុះពណ៌នៃសៀវភៅរូបភាពជប៉ុនដែលអ្នកអានជុំវិញពិភពលោកចូលចិត្ត។

*រូបថត៖ គីរីហារ៉ា អុសាមឺ*

**"ហ្វូស៊ិហ៊្គិណា អិ (រូបភាពចម្លែក)"**

(និពន្ធ និងគូរដោយ អានណុ មិត្ស៊ឺម៉ាសា/បោះពុម្ពផ្សាយដោយ ក្រុមហ៊ុន ហ្វូគុនកាន ស្យូតេន)

ពិភពលោកនូវរូបភាពបំភាន់ភ្នែកជាច្រើនដែលត្រូវបានបង្ហាញដោយមនុស្សតូចៗ។ រូបភាពទាំងអស់គ្មានអត្ថបទ។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាអង់គ្លេស។ សៀវភៅរូបភាពនេះបានបោះពុម្ពជាប្រាំពីរភាសារហូតមកដល់បច្ចុប្បន្ន។

"ស៊ីរ៉ុគីម៉ា ណុ ផាន់ត៉ឺ (ខោក្នុងរបស់ខ្លាឃ្មុំស)"

(និពន្ធ និងគូរដោយ tupera tupera /បោះពុម្ពផ្សាយដោយ ក្រុមហ៊ុនប្រនស៍)

ខ្លាឃ្មុំសមួយក្បាលបានបាត់ខោក្នុង ហើយស្វែងរកខោនោះដោយមានជំនួយពីកណ្ដុរ។ ល្បិចប្រទាក់ខោក្នុងទៅនៅលើផ្ទាំងក្រដាសក្នុងសៀវភៅរូបភាពនេះ គឺគួរឱ្យចាប់អារម្មណ៍ផងដែរ។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាអ៊ីតាលី។ សៀវភៅរូបភាពនេះ ត្រូវបានបោះពុម្ពជា១១ភាសារហូតមកដល់បច្ចុប្បន្ន។

"ម៉ូម៉ូតារ៉ូ (ក្មេងប្រុសផ្លែម៉ូម៉ូ)"

(និពន្ធដោយ ម៉ាត់ស៊ុអ៊ិ តាដាស៊ិ/ គំនូរដោយ អាកាបា ស៊ុអ៊ិគិឈិ/ បោះពុម្ពផ្សាយដោយ ក្រុមហ៊ុន ហ្វូគុនកាន ស្យូតេន)

សៀវភៅរូបភាពនេះផ្អែកលើរឿងនិទានជប៉ុនចំណាស់មួយ ដែលក្មេងប្រុសម៉ូម៉ូតារ៉ូ កើតចេញពីផ្លែម៉ូម៉ូ ឬផ្លែប៉ែសដែលធ្វើដំណើរជាមួយឆ្កែ ស្វា និងក្ងាន ដើម្បីកំចាត់យក្ស។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាចិន។ សៀវភៅរូបភាពនេះ ក៏ត្រូវបានបោះពុម្ពជាភាសាកូរ៉េផងដែរ។

"ស៊ូហុ ណុ ស៊ីរ៉ូយអ៊ុម៉ា (សេះសរបស់ស៊ូហុ)"

(និពន្ធដោយ អុត្ស៊ឹកា យូហ្សុ/ គំនូរដោយ អាកាបា ស៊ុអ៊ិគិឈិ/ បោះពុម្ពផ្សាយដោយ ក្រុមហ៊ុន ហ្វូគុនកាន ស្យូតេន)

រឿងរ៉ាវទាក់ទងនឹងទំនាក់ទំនងរវាងជនជាតិម៉ុងហ្គោលីម្នាក់ ឈ្មោះស៊ូហុ និងសេះស។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាបារាំង។ សៀវភៅរូបភាពនេះ ត្រូវបានបោះពុម្ពជា៩ភាសារហូតមកដល់បច្ចុប្បន្ន។

<u>ទំព័រទី១៣៖</u>

"គីនង្យ៉ុ ហ្គា និហ្គេតា (ត្រីក្រឹមមាសបានរត់គេច)"

(និពន្ធ និងគូរដោយ ហ្គុមិ តារ៉ូ/ បោះពុម្ពផ្សាយដោយ ក្រុមហ៊ុន ហ្វូគុនកាន ស្យូតេន)

តើត្រីក្រឹមមាសដែលបានរត់គេចខ្លួននៅឯណា? នេះជាសៀវភៅរូបភាពស្វែងរករូប ដែលអ្នកអាចរកឃើញត្រីក្រឹមមាសដែលលាក់ខ្លួននៅក្នុងរូបភាព។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាប៉ូឡូញ។ សៀវភៅរូបភាពនេះ ត្រូវបានបោះពុម្ពជា៨ភាសារហូតមកដល់បច្ចុប្បន្ន។

**"វ៉ាគឺហ្គាគិអិហុន ហ្គុមិតារ៉ូ៥០% (សៀវភៅរូបភាពគំនូរដាន, ផាត់ពណ៌ ហ្គុមិតារ៉ូ៥០%)"**

(និពន្ធ និងគូរដោយ ហ្គុមិ តារ៉ូ /បោះពុម្ពផ្សាយដោយ ក្រុមហ៊ុនប្រនស៍)

សៀវភៅរូបភាពដែលអ្នកអាចសរសេរ ឬ គូរដោយផ្ទាល់នៅលើសៀវភៅ។ អ្នកអាចសរសេរ ឬ គូរដោយសេរីតាមរូបភាព និងតួអក្សរ។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាអេស្ប៉ាញ។ សៀវភៅរូបភាពនេះត្រូវបានបោះពុម្ពជា១៧ភាសារហូតមកដល់បច្ចុប្បន្ន។

**"ស៊ិរ៉ុគឺម៉ាចាន ណុ ហាតតុខេក (នំផេនខេករបស់កូនខ្លាឃ្មុំស)"**

(និពន្ធ និងគូរដោយ វ៉ាកាយ៉ាម៉ា គេន / បោះពុម្ពផ្សាយដោយ ក្រុមហ៊ុនកុហ្គូម៉ា)

កូនខ្លាឃ្មុំសព្យាយាមធ្វើនំផេនខេកជាមួយម្ដាយ។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាចិន។ សៀវភៅរូបភាពនេះ ក៏ត្រូវបានបោះពុម្ពជាភាសាកូរ៉េជាដើមផងដែរ។

**"ហ្គោរី តុ ហ្គោរ៉ា (ហ្គោរី និង ហ្គោរ៉ា)"**

(និពន្ធដោយ ណាកាហ្គាវ៉ា រេកុ/ គំនូរដោយ យ៉ាម៉ាវ៉ាគិ យូរីកុ/ បោះពុម្ពផ្សាយដោយ ក្រុមហ៊ុន ហ្វូគុនកាន ស្យូតេន)

រឿងរ៉ាវអំពីកណ្ដុរព្រៃពីរក្បាល គឺ ហ្គោរី និង ហ្គោរ៉ា ដែលបានធ្វើនំពងទា(កាស៊ីតេរ៉ា) ចេញពីស៊ុតធំដែលពួកគេបានប្រទះឃើញក្នុងព្រៃ។ រូបថតដែលបង្ហាញក្នុងទស្សនាវដ្ដីនេះ គឺបោះពុម្ពជាភាសាអាឡឺម៉ង់។ សៀវភៅរូបភាពនេះត្រូវបានបោះពុម្ពជា១២ភាសារហូតមកដល់បច្ចុប្បន្ន។

*រូបឆ្វេងផ្នែកខាងលើ៖ កាបូប និងស្រោមជើង ជាមួយរូបភាពចេញពីរឿង"ស៊ិរ៉ុគឺម៉ាចាន ណុ ហាតតុខេក (នំផេនខេករបស់កូនខ្លាឃ្មុំស)"*

*រូបស្ដាំ៖ បង់ស្អិត និងអាវយឺតជាមួយរូបភាពចេញពីរឿង "គីនដូរ៉ុ ហ្គា និហ្គេតា (ត្រីក្រឹមមាសបានរត់គេច)"*

*រូបឆ្វេងផ្នែកលើទំព័រ១២៖ ហាងដែលមានឯកទេសខាងសៀវភៅរូបភាពអាចរកបាននៅទូទាំងទីក្រុងតូក្យូ ហើយហាងសៀវភៅខ្លះថែមទាំងមានហាងកាហ្វេផងដែរ។ រូបភាព១ និង២ គឺជា ហាងសៀវភៅកាហ្វេ (Book House Cafe) នៅជីមបូចូ ដែលមានសៀវភៅចំនួន១០,០០០ក្បាល និងហាងកាហ្វេមួយដែលមានគំនូរពិដានរូបព្រះអាទិត្យ និងព្រះច័ន្ទ។ រូបភាព៣ គឺ ផ្ទះគ្រូល័រទៀន (Crayonhouse) នៅអាអុយ៉ាម៉ា ដែលមានរុក្ខជាតិបៃតងខៀវស្រងាត់នៅពីមុខច្រកចូល។*

ទំព័រទី១៤៖

## ទស្សនាទីតាំង អានិមេ នៅក្នុងជីវិតពិត

អ្នកគាំទ្រអានិមេ កំពុងធ្វើដំណើរទៅទស្សនាកន្លែងនានាដែលបានបង្ហាញនៅក្នុងខ្សែភាពយន្ត និងរឿងភាគទូរទស្សន៍ដ៏ពេញនិយម។ ប្រសិនបើអ្នកទៅទស្សនាកន្លែងទាំងនោះ អ្នកក៏អាចឃើញខ្លួនឯងនៅក្នុងឈុតមួយដែលអ្នកចូលចិត្តដែរ។

"រឿងហ្យូកា"

**ផ្លូវផ្សារមិយ៉ាហ្គាវ៉ាអាសាអ៊ិឈិ (ទីក្រុងតាកាយ៉ាម៉ា ខេត្តហ្គិហ្វូ)**

"ហ្យូកា" គឺជារឿងដែលផលិតក្នុងឆ្នាំ២០១២ ជាប្រភេទរឿងភាគអាថ៌កំបាំង ដែលសាច់រឿងមានក្រុមសិស្សវិទ្យាល័យស្រីប្រុសបួននាក់បានដោះស្រាយរឿងអាថ៌កំបាំងដែលកើតឡើងជុំវិញពួកគេ។ ស្ថិតនៅក្នុងទីក្រុងតាកាយ៉ាម៉ា ខេត្តហ្គិហ្វូ ជាកន្លែងកំណើតរបស់អ្នកនិពន្ធប្រលោមលោក គឺលោក ហុណុប៊ុ យ៉ុណិហ្សាវ៉ា ដែលបានពណ៌នាយ៉ាងឥតខ្ចោះអំពីទេសភាពបរិយាកាសនៃទីក្រុង និងអគារបុរាណ។ រូបថតបង្ហាញពីផ្លូវផ្សារមិយ៉ាហ្គាវ៉ាអាសាអ៊ិឈិ នៅពេលព្រឹក តាមមាត់ទន្លេមិយ៉ាហ្គាវ៉ាដែលហូរកាត់កណ្តាលទីក្រុង។

©Yonezawa Honobu/KADOKAWA CORPORATION/Kamiyama Koko Kotenbu Alumni Association

"រឿងឈិហាយ៉ាហ្វូរី"

**ព្រះវិហារ អុមិ ជីនហ្គូ (ទីក្រុងអុត្ស៊ឺ ខេត្តស៊ីហ្គា)**

រឿងនេះផលិតក្នុងឆ្នាំ២០១១ ផ្តោតទៅលើការប្រកួតការីតា(ល្បែងប្រជាប្រិយជប៉ុន) ដែលតួឯក គឺក្មេងស្រីវ័យក្មេងដែលមានបំណងចង់ក្លាយជាអ្នកលេងការីតាលំដាប់ខ្ពស់បំផុតក្នុងចំណោមអ្នកលេងផ្សេងទៀត ហើយធ្វើការស្វែងយល់ពីការប្រាស្រ័យទាក់ទងគ្នា និងការប្រឈមមុខជាមួយមិត្តភក្តិ។ ការទាក់ទាញមួយក្នុងរឿងនេះ គឺការពណ៌នាលម្អិតនៃទំនៀមទម្លាប់របស់ជប៉ុនដូចជាកំណាព្យវ៉ាកា និងគីម៉ូណូ(សម្លៀកបំពាក់ប្រពៃណីជប៉ុន)។ ព្រះវិហារ អុមិ ជិនហ្គូ ដែលជាទីសក្ការបូជាឧទ្ទិសដល់អធិរាជតេនជិ ដែលជាអធិរាជដែលមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយការីតា។ ហើយសព្វថ្ងៃទីនេះនៅតែជាកន្លែងរៀបចំការប្រកួតការីតា។

©Suetsugu Yuki/KODANSHA LTD/VAP/NTV

ទំព័រទី១៥៖

"រឿងយ៉ារីក្យាន(ការបោះតង់ងាយៗ)"

**បឹងម៉ុតុស៊ុកុ (ទីក្រុងមិណុប៊ូ ខេត្តយ៉ាម៉ាណាសិ)**

រឿងនេះផលិតក្នុងឆ្នាំ២០១៨ ដែលបង្ហាញពីការបោះតង់ងាយៗរបស់ក្រុមសិស្សវិទ្យាល័យស្រីមួយក្រុមនៅពេលដែលពួកគេបោះតង់ និងដំណើរជីវិតប្រចាំថ្ងៃរបស់ពួកគេនៅក្នុងខេត្តយ៉ាម៉ាណាសិ។ ទេសភាពធម្មជាតិ និងទីប្រជុំជនជុំវិញខេត្តយ៉ាម៉ាណាសិត្រូវបានគូរយ៉ាងស្រស់ស្អាត ហើយរឿងនេះបានណែនាំអំពីអ្វីៗទាំងអស់ដែលទាក់ទងនឹងការបោះតង់ រួមទាំងសីលធម៌ក្នុងការបោះតង់ និងរបៀបប្រើប្រាស់ឧបករណ៍នានាផងដែរ។ រូបថតនេះ គឺជាកន្លែងបោះតង់កូអាន ដែលអាចឱ្យយើងបានឃើញទិដ្ឋភាពភ្នំហ្វូជិ និងបឹងម៉ុតុស៊ុកុ។

©Afro, HOUBUNSHA Co., Ltd. / Yagai Katsudo Circle Photo courtesy of Mt. Fuji Yamanashi Film Commission

"រឿងអាណុហ៊ិ មិតា ហានា ណុ ណាម៉ាអិ អុ ប៉ុគឺតាឈិ វ៉ា ម៉ាដា ស៊ិរ៉ាណៃ(ផ្កាដែលយើងបានឃើញនៅថ្ងៃនោះមិនទាន់បានស្គាល់ឈ្មោះ)"

**ស្ថានចាស់ ឈិឈិប៊ូ (ទីក្រុងឈិឈិប៊ូ ខេត្តសៃតាម៉ា)**

រឿងនេះនិយាយពីអតីតមិត្ត៥នាក់បានជំនះលើជម្លោះរវាងគ្នានឹងគ្នា នៅពេលព្រលឹងខ្មោចមិត្តកាលពីកុមារភាពម្នាក់បានបង្ហាញខ្លួននៅចំពោះមុខតួឯក។ រឿងនេះ បានរំលេចឡើងនូវអគារ និងទេសភាពពិតៗជាច្រើនរបស់ទីក្រុងឈិឈិប៊ូ ក្នុងខេត្តសៃតាម៉ា។ រូបថតនេះ គឺជាស្ថានចាស់ឈិឈិប៊ូ ដែលជានិមិត្តសញ្ញាមួយនៃទីក្រុងឈិឈិប៊ូ ដែលបានបើកឱ្យចរាចរណ៍នៅឆ្នាំ១៩៣១។

©ANOHANA PROJECT

<u>ទំព័រទី១៦៖</u>

## ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ តួអង្គគំនូរជីវចលនៅតាមផ្លូវនៃប្រទេសជប៉ុន

នៅទូទាំងប្រទេសជប៉ុន តួអង្គគំនូរជីវចល ម៉ានហ្គា អានិមេ និងភាពយន្តបានលោតចេញពីសន្លឹកក្រដាស មកនៅតាមដងផ្លូវក្នុងពិភពពិត ហើយក្លាយជានិមិត្តសញ្ញានៃទីក្រុងដែលត្រូវបានអ្នកក្នុងតំបន់ស្រឡាញ់ពេញចិត្ត។

**ខេត្តស៊ីហ្គា "ប៉ូកិម៉ុនម៉ានស្នើ"**

ពីហ្គេមវីដេអូរហូតដល់អានិមេ និងកាតពាណិជ្ជកម្ម តួអង្គដែលប្លែក និងរួសរាយ គឺ"ប៉ុកិម៉ុន" ដ៏មានប្រជាប្រិយភាពត្រូវបានលេចឡើងនៅលើគម្របលូនៅទូទាំងប្រទេសជប៉ុន។ គម្របលូប៉ុកិម៉ុនជាច្រើននៅទូទាំងប្រទេស ដូចជា គម្របរូប "ហ្គេកកូហ្គា" ក្នុងទីក្រុងកូហ្គា ខេត្តស៊ិហ្គា និង គម្របរូប "ពិកាជូ" នៅទីក្រុងយ៉ុកុហាម៉ា ជាដើម។

©Pokémon.©Nintendo/creatures Inc./GAME FREAK inc. ©2022 Pokémon. ©1995-2022 Nintendo/Creatures Inc./GAME FREAK inc.

Pocket Monsters, Pokemon *និង* Pokémon *ទាំងអស់គឺជាពាណិជ្ជសញ្ញាដែលបានចុះបញ្ជីរបស់ក្រុមហ៊ុន* Nintendo *និង* Creatures Game Freak *។*

**ខេត្តហ្វូគឺអុកា "ហ្គីនហ្គាតិត្សឺដូ៩៩៩ (ផ្លូវដែកកាឡាក់ស៊ី៩៩៩)"**

"ហ្គីនហ្គាតិត្សឺដូ" គឺជាអានិមេបែបវិទ្យាសាស្ត្រដែលប្រាប់ពីរឿងរ៉ាវរបស់តួអង្គឯកពីរនាក់គឺ ហុស៊ិណុ តិត្សឺរ៉ុ(ខាងស្តាំ) និង មេតេរឺ(ខាងឆ្វេង) ដែលធ្វើដំណើរឆ្លងកាត់លំហអាកាស ដើម្បីស្វែងរកតួម៉ាស៊ីនសម្រាប់ក្មេងប្រុស។ រូបសំណាករបស់តួទាំងពីរតាំងនៅស្ថានីយ៍កុគឺរ៉ា ក្នុងទីក្រុងគិតាគ្យូស្យ៊ូ ខេត្តហ្វូគឺអុកា ដែលជាស្រុកកំណើតរបស់អ្នកនិពន្ធ លោក ម៉ាត្សឺម៉ុតុ ឡិអ៊ិជិ។

©Matsumoto Leiji/Leiji-sha

**ខេត្តគឺម៉ាម៉ុតុ "វ៉ានភីស(កំណាប់មួយ)"**

លូហ្វី គឺជាតួឯកក្នុងរឿង"វ៉ានភីស" ដែលមានសុបិនចង់ក្លាយជាស្តេចចោរសមុទ្រ ហើយបន្តដំណើរផ្សងព្រេង។ រឿងនេះបានគាំទ្រតំបន់រងគ្រោះដោយការរញ្ជួយដីដ៏ធំក្នុងឆ្នាំ២០១៦ ដល់ទីក្រុងគឺម៉ាម៉ុតុ។ ហើយជាផ្នែកមួយនៃ "គម្រោងសាងសង់ឡើងវិញ វ៉ានភីស គឺម៉ាម៉ុតុ" រូបសំណាកតួអង្គផ្សេងៗក្នុងរឿងនេះបានសាងសង់ឡើងវិញ ទូទាំងខេត្តគឺម៉ាម៉ុតុ រួមទាំងរូបសំណាកលូហ្វី ក្នុងទីក្រុងគឺម៉ាម៉ុតុ។ ©Oda Eiichiro/Shueisha Inc.

ទំព័រទី១៧៖

**ខេត្តគុយ៉ាម៉ា "ដុរ៉ាអិម៉ុន"**

ស្នាដៃនិពន្ធដោយលោកហ្វូជិកុ អេហ្វ ហ្វូជិអុ ដែលពណ៌នាពីជីវិតប្រចាំថ្ងៃរបស់ក្មេងប្រុសបឋមសិក្សាម្នាក់ឈ្មោះណុប៊ិតា និងដុរ៉ាអិម៉ុនដែលជាមនុស្សយន្តរូបរាងឆ្មាមកពីសតវត្សទី២២។ នៅស្រុកកំណើតរបស់អ្នកនិពន្ធ នៅទីក្រុងតាកាអុកា ខេត្តគុយ៉ាម៉ា នៅទីធ្លាដីទំនេរមួយបានលេចរូបរាងតួអង្គក្នុងរឿងនេះឡើង។

©Fujiko F. Fujio Production

**ខេត្តហ្វូគឺស៊ិម៉ា "អ៊ុលត្រាម៉ាន"**

អ៊ុលត្រាម៉ាន ដែលមកពីណេប៊ូឡា M78 ដ៏ឆ្ងាយ ដើម្បីការពារសន្តិភាពក្នុងសកលលោក បានបំពេញបេសកកម្មនៅទីក្រុងស៊ុកាហ្គាវ៉ា ខេត្តហ្វូគឹស៊ីម៉ា។ វាជាស្រុកកំណើតរបស់អ្នកបង្កើតវីរបុរសអ៊ុលត្រាម៉ាន គឺលោកត្ស៊ឹប៊ូរ៉ាយ៉ា អិអ៊ិជិ ហើយក៏ជាកន្លែងកំណើតរបស់"សារមន្ទីរត្ស៊ឹប៊ូរ៉ាយ៉ា អិអ៊ិជិ" ដែលបង្ហាញពីសមិទ្ធិផល និងការទាក់ទាញរបស់អ្នកដឹកនាំរឿងផងដែរ។

©TSUBURAYA PRODUCTIONS Co., Ltd.

**តូក្យូ "ហ្គោជិឡា"**

ហ្គោជិឡា គឺជាសត្វចម្លែកដ៏ធំសម្បើមដែលផុសចេញពីសមុទ្រ ហើយបំផ្លាញទីក្រុងនានា ដែលបង្ហាញខ្លួននៅក្នុងទីប្រជុំជនស៊ីនជូគឺ ទីក្រុងតូក្យូ។ រូបសំណាកក្បាលរបស់ហ្គោជិឡាបានលេចឡើងនៅក្នុងចំណោមអគារក្នុងទីក្រុងដែលជាទិដ្ឋភាពពោរពេញដោយថាមពល ដែលមើលទៅហាក់បីដូចជាសត្វចម្លែកនៅតែបំផ្លិចបំផ្លាញទីក្រុង។

TM & ©TOHO CO., LTD

**តូក្យូ "ខ្សាពីតេន ត្ស៊ឹបាសា(មេក្រុមត្ស៊ឹបាសា)"**

រឿងភាគម៉ានហ្គាដែលពណ៌នាពីក្មេងប្រុសត្ស៊ឹបាសា អូហ្សូរ៉ា ដែលសកម្មលើកីឡាបាល់ទាត់នៅលើឆាកអន្តរជាតិជាមួយអ្នកចាំទីដ៏ឆ្នើមគឺ ហ្គេនហ្ស៊ុ វ៉ាកាបាយ៉ាស៊ិ។ រូបសំណាកក្មេងប្រុសត្ស៊ឹបាសា ឈរនៅ ខណ្ឌកាត្ស៊ឹស៊ិកា ទីក្រុងតូក្យូ ដែលជាស្រុកកំណើតរបស់អ្នកនិពន្ធ លោក តាកាហាស៊ិ យ៉ុអ៊ីឈិ។

© Yoichi Takahashi / SHUEISHA

**ខេត្តតុតតុរី "មេតានតេ កុណាន(អ្នកស៊ើបអង្កេតកុណាន)"**

"អ្នកស៊ើបអង្កេតកុណាន" ជារឿងម៉ាន់ហ្គានិយាយពីអ្នកស៊ើបអង្កេតវិទ្យាល័យម្នាក់ បានប្រែរូបរាងកាយក្លាយជាក្មេងប្រុស ដោយសារតែថ្នាំអាថ៌កំបាំងមួយ។ សារមន្ទីរចងចាំ រួមជាមួយរូបសំណាក់តួឯក កុណាន ឈរនៅក្នុងទីប្រជុំជន ហុគឹអេ ខេត្តតុតតុរី ដែលជាស្រុកកំណើតរបស់អ្នកនិពន្ធ លោក អាអុយ៉ាម៉ា ហ្គោស្ស៉ូ។

©Aoyama Gosho/SHOGAKUKAN Inc.

**ខេត្តកាណាហ្គាវ៉ា "គិដូ សេនសុិ ហ្គានដាមឹ (មនុស្សយន្តហ្គានដាំ)"**

រឿង គិដូ សេនសុិ ហ្គានដាមឹ ពណ៌នាពី ក្មេងប្រុសជំទង់អាមឺរ៉ុ ជាមួយមនុស្សយន្តហ្គានដាំ និងដៃគូប្រយុទ្ធគឺឆារ។ អ្នកទេសចរ អាចទស្សនាមនុស្សយន្តហ្គានដាំ ដែលមានទំហំពិតជាក់ស្តែង និងអាចធ្វើចលនាបាន នៅទីក្រុងយ៉ុកុហាម៉ា ខេត្តកាណាហ្គាវ៉ា។ ការទស្សនាជាសាធារណៈនេះបើករហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

©SOTSU CO., LTD./SUNRISE

<u>ទំព័រទី១៨៖</u>

## រសជាតិជប៉ុន ៖ ពេលវេលាទទួលទាន! កាស៊ឹតេរ៉ា(នំពងទា)㉒

នំដុតដែលមានកំណើតនៅក្នុងទីក្រុងកំពង់ផែដែលចូលចិត្តដោយអ្នកនិពន្ធដ៏ឆ្នើម

*រូបថត៖ អារ៉ៃ អាគិកុ*

*១. "ណាហ្គាសាគិ កាស៊ឹតេរ៉ា" របស់ហាងប៊ុនមុិអុិដុ សុហុនតេន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នំកាស៊ឹតេរ៉ា ភាគច្រើនត្រូវបានកាត់ជាចំណិតៗដើម្បីធ្វើឱ្យកាន់តែងាយស្រួលក្នុងការទទួលទាន។*

*២. "ម៉ុម៉ុ កាស៊ឹតេរ៉ា(នំពងទារូបផ្លែម៉ុម៉ុ)" គឺជាកាស៊ឹតេរ៉ា ស្រោបស្ករផ្អែម ដែលជានំប្រពៃណីរបស់ខេត្តណាហ្គាសាគិ សម្រាប់ពេលប្រារព្ធពិធី។*

*៣. "វ៉ាហ្គាហាអិ វ៉ា ណិកុ ដិ អារឺ (ខ្ញុំជាឆ្មា)" គឺជាប្រលោមលោកបែបកំប្លែងដែលមាន"គឺរ៉ុណិកុ (ឆ្មាខ្មៅ)"ជាតួឯក ដែលរៀបរាប់អំពីគ្រួសារម្ចាស់ឆ្មា និងមនុស្សជុំវិញ។ រឿងនេះត្រូវបានបោះពុម្ពលើកដំបូងនៅឆ្នាំ១៩០៥។ (ប្រមូលចងក្រងដោយសារមន្ទីរចងចាំសុសិគិណាត្សឹមុិ)*

*៤. ហាង ប៊ុនមុិអុិដុ សុហុនតេន បង្កើតឡើងក្នុងឆ្នាំ១៩០០ ដែលនៅរក្សារចនាបថបុរាណនៃប្រវត្តិសាស្ត្រហាងនំផ្អែម។ ហាងនំកាស៊ឹតេរ៉ាជាង១០០ហាង មាននៅក្នុងខេត្តណាហ្គាសាគិ។*

*រូបស្តាំ៖ អ្នកនិពន្ធដ៏ឆ្នើមលោក សុសិគិ ណាត្ស៊ឹមិ ចូលចិត្តនំកាស៊ឹតេរ៉ា។ ចំណុចពិសេសនៃនំកាស៊ឹតេរ៉ា គឺមានរសជាតិផ្អែមមុត និងទន់ល្មើយ។*

កាស៊ឹតេរ៉ា គឺជានំពងទាដែលមានរូបរាងដូចអេប៉ុង ធ្វើពីម្សៅ ស៊ុត និងស្ករ ហើយដុតជារាង៤ជ្រុង។ ជាទូទៅវាត្រូវបានលក់ក្នុងប្រអប់មួយ ដោយកាត់ជាចំណិតទទឹងប្រហែល៣សង់ទីម៉ែត្រ ដើម្បីងាយស្រួលពេលទទួលទាន។ នំកាស៊ឹតេរ៉ា មានដើមកំណើតនៅខេត្តណាហ្គាសាគិ ក្នុងតំបន់គ្យូស្យ៊ូ ប្រទេសជប៉ុន។ ស្ថិតនៅចុងភាគខាងលិចនៃប្រទេសជប៉ុន តំបន់នេះបានបើកជាកំពង់ផែពាណិជ្ជកម្មនៅចុងសតវត្សទី១៦ ហើយក្រោយមកវាជាច្រកពាណិជ្ជកម្មតែមួយគត់ក្នុងអំឡុងពេល ស្យូហ្គុំណាតិ តុគឹហ្គាវ៉ា ដែលបិទប្រទេសដោយហាមឃាត់ចរាចរណ៍ និងរឹតបន្តឹងពាណិជ្ជកម្មជាមួយបរទេស។

នំកាស៊ឹតេរ៉ា ត្រូវបានគេនិយាយថាមានប្រភពចេញពីនំដែលណែនាំដោយអ្នកផ្សព្វផ្សាយសាសនាព័រទុយហ្គាល់ក្នុងសតវត្សរ៍ទី១៦ មុនពេលជប៉ុនបិទប្រទេស។ តែក៏មានការយល់ឃើញថានៅក្នុងប្រទេសព័រទុយហ្គាល់ហៅថា "pão de ló" និងហៅថា "bizcocho" នៅក្នុងប្រទេសអេស្ប៉ាញ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ នំកាស៊ឹតេរ៉ា ត្រូវបានបង្កើតឡើងនៅណាហ្គាសាគិ ក្នុងទសវត្សរ៍ឆ្នាំ១៦២០ ហើយបានរីករាលដាលពាសពេញប្រទេសជប៉ុន។

អ្នកនិពន្ធអក្សរសិល្ប៍ដែលទាក់ទងយ៉ាងជិតស្និទ្ធជាមួយនំកាស៊ឹតេរ៉ា គឺ លោក សុសិគិ ណាត្ស៊ឹមិ(១៨៦៧-១៩១៦) ដែលត្រូវបានគេហៅថាជាបិតានៃអក្សរសិល្ប៍ជប៉ុនទំនើប។ លោកសុសិគិ កើតនៅពេលដែលជប៉ុនបញ្ចប់ភាពឯកោរបស់ខ្លួន ហើយចាប់ផ្តើមឈានទៅមុខជាប្រទេសទំនើប ហើយស្នាដៃរបស់លោកបានឆ្លុះបញ្ចាំងពីជម្លោះដែលកើតចេញពីភាវូបនីយកម្មយ៉ាងឆាប់រហ័សនៃប្រទេសជប៉ុន។ ខ្លួនលោកផ្ទាល់ចូលចិត្តនំផ្អែម ហើយបានធ្វើឱ្យកាស៊ឹតេរ៉ាលេចមុខក្នុងស្នាដៃប្រលោមលោករបស់លោកមួយចំនួន។ ជាក់ស្តែងក្នុងរឿង "វ៉ាហ្គាហាអិ វ៉ា ណិកុ ដិ អារី (ខ្ញុំជាឆ្មា)" លោកបានពណ៌នាដោយកំប្លែងសរសេរពីទស្សនៈឆ្មាគិតអំពីភ្មៀវវ័យក្មេងម្នាក់កំពុងលួចញ៉ាំនំកាស៊ឹតេរ៉ា ខណៈដែលម្ចាស់ផ្ទះនៅឆ្ងាយពីកន្លែងអង្គុយ។

លោក សុសិគិ ក៏បានសរសេរនៅក្នុងកំណត់ហេតុរបស់លោកអំពីពេលដែលលោកបានទៅលេងមិត្តម្នាក់នៅក្យូតុ ហើយទទួលបាននំកាស៊ឹតេរ៉ាជាអំណោយអនុស្សាវរីយ៍។ "ក្រឡេកមើលទៅវត្តប្រាំជាន់(ហ្គុយូណុតូ) ទល់នឹងមេឃនានិទាឃរដូវដ៏កក់ក្តៅ / វង្វេងជុំវិញដោយក្តីស្រលាញ់ចំពោះនំកាស៊ឹតេរ៉ា" វាជាឃ្លាដ៏កក់ក្តៅដែលរំឭកយើងពីលោកសុសិគិបានដើរជុំវិញរាជធានីបុរាណ ជាមួយនំកាស៊ឹតេរ៉ា ដែលគាត់ចូលចិត្តពេញបេះដូង។

លោកណាកាហ្គាវ៉ា យ៉ាស៊ូហិដិ ប្រធានហាងប៊ុនមិអិដុ សុហុនតេន ដែលជាហាងនំកាស៊ឹតិរ៉ា ដែលត្រូវបានបង្កើតឡើងជាយូរមកហើយនៅណាហ្គាសាគិ មានប្រសាសន៍ថា នំកាស៊ឹតិរ៉ាមិនមានរសជាតិដូចសព្វថ្ងៃនេះទេ រហូតដល់ចុងសតវត្សទី១៩ ដែលមិហ្ស៊ឹអាម៉ិ(ទឹកស្ករ)ត្រូវបានបន្ថែមទៅក្នុងគ្រឿងផ្សំ។ "ការបន្ថែមទឹកស្ករនេះធ្វើឱ្យម្សៅ

នំមានសំណើម។ ប្រជាជនជប៉ុនមិនចូលចិត្តសាច់នំស្ងួតនោះទេ។ ដោយការបន្ថែមទឹកស្ករទៅក្នុងម្សៅនំកាស៊ីតិរ៉ា ដែលដើមឡើយជានំរបស់អឺរ៉ុប វាក៏បានក្លាយទៅជានំផ្អែមរបស់ជប៉ុន"។ ដើម្បីធានាបាននូវសាច់នំដែលមានសំណើម ម្សៅត្រូវបានកូរច្រើនដងសូម្បីតែក្នុងអំឡុងពេលដុតនំក៏ដោយ។ ធ្វើបែបនេះទើបធ្វើឱ្យនំឆ្អិនស្មើល្អ និងមានសំណើមសព្វ។

នំកាស៊ីតេរ៉ា ជារឿយៗនៅតែប្រើសម្រាប់ជាអំណោយ និងវត្ថុអនុស្សាវរីយ៍នៅក្នុងប្រទេសជប៉ុននាពេលបច្ចុប្បន្ន។ នំកាស៊ីតេរ៉ានៅតែមានប្រជាប្រិយភាពជាបន្តបន្ទាប់ បើទោះបីជាមានការកើនឡើង និងការធ្លាក់ចុះក្នុងចំណោមនំផ្អែមភាគច្រើនក៏ដោយ។ សៀវភៅ និងអក្សរសិល្ប៍ដែលឆ្លុះបញ្ចាំងយ៉ាងខ្លាំងពីចំណុចរបត់នៃប្រវត្តិសាស្ត្រ នឹងបន្តទាក់ទាញប្រជាជនជប៉ុនដោយមិនឱ្យនំនេះបាត់រូបរាងឡើយ។

<u>ទំព័រទី១៩</u>៖

<u>ទំព័រទី២០</u>៖

## ដើរកំសាន្តប្រទេសជប៉ុន㉓៖ ម៉ាត់ស៊ុយ៉ាម៉ា

ទីក្រុងដែលពេញទៅដោយកំណាព្យហៃគឺ និងទឹកក្តៅធម្មជាតិ(អុនសេន)

ម៉ាត់ស៊ុយ៉ាម៉ា បានរីកចម្រើនតាំងពីយូរលង់ណាស់មកហើយ ជាទីក្រុងមួយដែលមានប្រភពទឹកក្តៅធម្មជាតិដ៏ល្បីល្បាញបំផុតមួយរបស់ប្រទេសជប៉ុន ហើយជាកន្លែងពិសិដ្ឋសម្រាប់អក្សរសិល្ប៍ និងជាកន្លែងកំណើតរបស់កវីកំណាព្យហៃគឺ គឺលោក ម៉ាសាអុកា ស៊ិគិ។ នៅទីនេះ ជាកន្លែងដែលអានកំណាព្យ ជាមួយពពុះចំហាយទឹកក្តៅឧណ្ហៗ ដែលធ្វើឱ្យអ្នកទស្សនាអាចសម្រាកលំហែយ៉ាងស្រួលជាមួយពេលវេលានេះ។

*(រូបថត៖ គីរីហារ៉ា អុសាមឺ PIXTA បណ្ណាល័យរូបថត)*

<u>ទំព័រទី២១</u>៖

*១. "ដូហ្គុអុនសេនហុនកាន" ត្រូវបានគេនិយាយថាជាគំរូមួយសម្រាប់កន្លែងត្រាំទឹកក្តៅនៅក្នុងស្ទូឌីយ៉ូ ហ្គីប្លី នៃខ្សែភាពយន្តគំនូរជីវចលរឿង"សេនតុ ឈិហ៊ីរ៉ូ ណុ កាអុណាស៊ិ"។ (រូបរាងស្ថាបត្យកម្មខាងក្រៅ សហការជាមួយ "Phoenix"កំឡុងពេល "គម្រោង Dogo Reborn"។ គម្រោងនេះបានបញ្ចប់ហើយ ហើយរូបរាងស្ថាបត្យកម្មខាងក្រៅក៏ផ្លាស់ប្តូរផងដែរ។)*

*២. "កាមិ ណុ យឺ (ទេពទឹកក្តៅ)" នៅក្នុង"ដូហ្គុអុនសេនហុនកាន"។ ផ្ទាំងគំនូរសេរ៉ាមិចនៃសត្វកុកសមួយគូត្រូវបានបិទជាប់នឹងជញ្ជាំង។ (គិតត្រឹមឆ្នាំ២០២២ ការងារអភិរក្ស និងជួសជុលកំពុងដំណើរការ។ រូបថតដោយទីក្រុងម៉ាត់ស៊ុយ៉ាម៉ា)*

*៣. "អ៊ីយ៉ុតេត្ស៊ឺ" គឺជារថភ្លើងរត់កាត់ទីក្រុង។ ខ្លះត្រូវបានយកគំរូតាមក្បាលរថភ្លើងដុតអុស។*

*៤. រូបសំណាកកុកសនៅលើដំបូល "ដូហ្គុអុនសេនហុនកាន"។ វាបានក្លាយជានិមិត្តរូបនៃ "ដូហ្គុអុនសេន"ដោយសារតែរឿងព្រេងនិទានថាសត្វកុកបានព្យាបាលរបួសដោយប្រភពទឹកក្តៅនៅទីនេះ។ (រូបថតដោយទីក្រុងម៉ាត្ស៊ុយ៉ាម៉ា)*

*៥. "បុតចាន ដានហ្គុ" ត្រូវបានដាក់ឈ្មោះតាមប្រលោមលោករបស់លោក សុសិគិ ណាត្ស៊ុមិ ចំណងជើងថា "បុតចាន" ដែលមានក្នុងទីក្រុងម៉ាត្ស៊ុយ៉ាម៉ា។*

<u>ទំព័រទី២២៖</u>

*៦. ផ្ទាំងថ្មដែលមានកំណាព្យហៃគឺ របស់លោក ម៉ាសាអុកា ស៊ិគិ ឈរនៅពីមុខស្ថានីយ៍ម៉ាត្ស៊ុយ៉ាម៉ា។ "និទាឃរដូវ និងសម័យបុរាណអង្គរ១៥ម៉ឺនកុគឹ(១កុគឹ ប្រហែល១៨០គីឡូក្រាម) ទីក្រុងក្បែរប្រាសាទ"មានន័យធៀបថា រដូវផ្ការីកសម័យបុរាណ ទីក្រុងក្បែរប្រាសាទមានដីធំទូលាយដែលនាំឱ្យទទួលបានស្រូវអង្ករយ៉ាងច្រើន។ កំណាព្យនេះបង្ហាញពីទីក្រុងម៉ាត្ស៊ុយ៉ាម៉ា។*

*៧. "ហៃគឺ ប៉ុស៊ឹតុ(ប្រអប់ប្រៃសណីយ៍កំណាព្យ)" ត្រូវបានដំឡើងនៅ៩០កន្លែងនៅក្នុងទីក្រុង រួមទាំងនៅបរិវេណប្រាសាទម៉ាត្ស៊ុយ៉ាម៉ា។ ទម្រង់បែបបទសម្រាប់ការបញ្ជូនកំណាព្យទៅក្នុងប្រអប់ប្រៃសណីយ៍មានភាសាផ្សេងៗជាច្រើន។*

*៨. "ប្រាសាទម៉ាត្ស៊ុយ៉ាម៉ា" ឈរនៅលើភ្នំស៊ីរ៉ុយ៉ាម៉ាដែលមានកម្ពស់១៣២ម៉ែត្រ។ អ្នកអាចមើលឃើញទេសភាពទីក្រុងពីប្រាសាទ។*

ទីក្រុងម៉ាត្ស៊ុយ៉ាម៉ា ក្នុងខេត្តអិហ៊ីមុ គឺជាទីក្រុងធំបំផុតនៅក្នុងតំបន់ស៊ិកុគឺ ដែលមានទីតាំងនៅភាគនិរតីនៃប្រជុំកោះជប៉ុន។ បែរមុខទៅសមុទ្រសិតុណៃកៃភាគខាងលិចមានភាពស្ងប់ស្ងាត់ ហើយតំបន់នេះមានអាកាសធាតុក្តៅពេញមួយឆ្នាំ។ រថយន្តបរយឺតៗតាមដងផ្លូវដោយឆ្លងកាត់កណ្តាលទីក្រុង នៅជុំវិញប្រាសាទម៉ាត្ស៊ុយ៉ាម៉ា ដែលត្រូវបានសាងសង់ឡើងក្នុងសម័យអេដុ(១៦០៣-១៨៦៨) គឺជាទិដ្ឋភាពប្រចាំថ្ងៃនៅក្នុងទីក្រុងដ៏ស្ងប់ស្ងាត់នេះ។

"ដូហ្គុអុនសេន" គឺជានិមិត្តសញ្ញារបស់ទីក្រុងម៉ាត្ស៊ុយ៉ាម៉ា។ ប្រភពទឹកក្តៅដែលមានប្រវត្តិយូរអង្វែងនេះត្រូវបានលើកឡើងនៅក្នុងសៀវភៅប្រវត្តិសាស្ត្រចំណាស់បំផុតរបស់ប្រទេសជប៉ុន"និហុនស្សូគិ" និងនៅក្នុងរឿងនិទានហ្គេនជិ (មើលទំព័រទី៤) ដែលបានសរសេរក្នុងសតវត្សរ៍ទី១១។ សព្វថ្ងៃ អ្នកទេសចរអាចរីករាយជាមួយ"ដូហ្គុអុនសេនហុនកាន"ដ៏ល្បីល្បាញ ព្រមទាំងកន្លែងងូតទឹកសាធារណៈ និងកន្លែងត្រាំជើងជាដើមផ្សេងៗទៀត។

ប្រសិនបើអ្នកដើរជុំវិញទីក្រុង អ្នកនឹងឃើញគឺហ៊ិ(ផ្ទាំងថ្មដែលមានឆ្លាក់កំណាព្យ)ផ្សេងៗ។ នេះគឺដោយសារតែ ម៉ាត្ស៊ុយ៉ាម៉ា ត្រូវបានគេស្គាល់ថាជា"រាជធានីនៃកំណាព្យហៃគឺ" និងជាស្រុកកំណើតរបស់ លោក ម៉ាសាអុកា ស៊ិគិ ដែលជាកវីដ៏ល្បីល្បាញម្នាក់ដែលបានបង្កើតនិន្នាការថ្មីនៃកំណាព្យហៃគឺកំឡុងសម័យមេជិ(១៨៦៨-១៩១២)។ ហៃគឺ គឺជាទម្រង់នៃកំណាព្យដែលមានដើមកំណើតនៅក្នុងប្រទេសជប៉ុន ហើយជាទម្រង់អក្សរសិល្ប៍ដែលបង្ហាញអក្សរសរុបចំនួន១៧ព្យាង្គ ឃ្លានីមួយៗមាន ៥ព្យាង្គ, ៧ព្យាង្គ, និង ៥ព្យាង្គ ដោយតាក់តែងឃ្លាឃ្លោងតាមពាក្យ

រដូវកាល (ពាក្យ ឬឃ្លាដែលបង្ហាញពីរដូវកាលជាក់លាក់មួយ)។ កំណាព្យហៃគឺ ធ្វើឱ្យអ្នកអានគិតពិចារណាអំពីការផ្លាស់ប្តូរនៃរដូវកាលទាំងបួន និងស្តាប់ពីអារម្មណ៍នាពេលនោះ។ កំណាព្យហៃគឺ ជាទម្រង់កំណាព្យខ្លីបំផុតមួយរបស់ពិភពលោក ដែលជាវិធីបង្ហាញទឹកចិត្តរបស់ខ្លួនយ៉ាងសាមញ្ញ បានកំពុងតែពេញនិយមក្នុងចំណោមមនុស្សជំនាន់ក្រោយក្នុងប៉ុន្មានឆ្នាំនេះ។

*៩. "ព្រះវិហារអ៊ីយ៉ូហ្ស៊ឺ ហ៊ីកុ ណុ មិកុតុ" ត្រូវបានគេស្គាល់ជាទូទៅថាជាព្រះវិហារត្ស៊ឹបាគិ(ត្ស៊ឹបាគិជាឈ្មោះផ្កាម្យ៉ាងដែលមានពណ៌ក្រហមស្រស់) ។ បន្ទះឈើនៅព្រះវិហារនេះ សម្រាប់ភ្ញៀវសរសេរពាក្យជូនពរ ឬ សេចក្តីប្រាថ្នា ក៏មានរាងដូចផ្កាត្ស៊ឹបាគិដែរ។*

*១០. "ស្ថានីយ៍ស៊ិម៉ុណាដា"នៅលើខ្សែរថភ្លើង JR Shikoku Yosan រត់នៅតាមឆ្នេរសមុទ្រសិតុណៃកៃ។ (រូបថតផ្តល់សិទ្ធិដោយ JR ស៊ិកុគឹ)*

*១១. អ៊ុឈិកុហ្សា គឺជារោងមហោស្រពឈើដែលសាងសង់នៅដើមសតវត្សរ៍ទី២០។ (រូបថតផ្តល់សិទ្ធិដោយក្រុងអ៊ុឈិកុ)*

<u>ទំព័រទី២៣</u>៖

*១២,១៣. "10FACTORY" ជាកន្លែងដែលអ្នកអាចភ្លក់រសជាតិទឹកក្រូចច្របាច់ជាច្រើនប្រភេទដូចជាទឹកក្រូចអ៊ុនស្ស៊ូ និងអ៊ិយ៉ុកាន*

*១៤. ណាបិយ៉ាគិ អ៊ុដុន(ស៊ុបឆ្នាំងដីមីអ៊ុដុន) មាននៅភោជនីយដ្ឋាន កុគុរិ។ ជាធម្មតាស៊ុបមីនេះតែងកំណាត់ក្នុងបញ្ជីម្ហូបរួមជាមួយអ៊ិណារិហ្ស៊ឺស៊ិ (បាយស៊ូស៊ីស្រោបតៅហ៊ូបំពង) រូបនៅខាងឆ្វេង។*

*១៥. តៃមិស៊ិ ចម្អិនក្នុងឆ្នាំងដី នៅភោជនីយដ្ឋានអាកា។*

ប្រសិនបើអ្នកចាប់អារម្មណ៍លើកំណាព្យហៃគឹ នោះជាការសប្បាយរីករាយបើអ្នកសាកល្បងតែងកំណាព្យមួយ។ សម្រាប់ភាសាបរទេស ក្បួនតាក់តែង គឺត្រូវប្រើ១៧ព្យាង្គ។ ក្រឡេកមើលទិដ្ឋភាពជុំវិញអ្នក ហើយព្យាយាមពណ៌នាទេសភាពនោះដោយប្រើពាក្យនៃរដូវកាល។ អ្នកក៏អាចដាក់កំណាព្យផ្ទាល់ខ្លួនរបស់អ្នកទៅកាន់"ហៃគឺប៉ុស៊ឹតុ (ប្រអប់ប្រៃសណីយ៍កំណាព្យ)" ដែលបានបង្កើតឡើងនៅកន្លែងផ្សេងៗក្នុងទីក្រុងម៉ាត្ស៊ឺយ៉ាម៉ាបានដែរ។ កំណាព្យនោះ នឹងត្រូវត្រួតពិនិត្យដោយគណៈកម្មាធិការជ្រើសរើស ហើយកវីដែលឈ្នះរង្វាន់ នឹងទទួលបានកាដូអនុស្សាវរីយ៍។ កំណាព្យហៃគឺ ដែលត្រូវបានជ្រើសរើសជាភាសាបរទេសកំពុងកើនឡើង ដូច្នេះសូមសាកល្បងកុំបីខាន។

ប្រសិនបើដើរបន្តិចនៅកណ្តាលទីក្រុង អ្នកនឹងបានឃើញព្រះវិហារអ៊ីយ៉ូហ្ស៊ឺ ហ៊ីកុ ណុ មិកុតុ ដែលឧទ្ទិសដល់ អាទិទេព អិហ៊ីមុ ណុ មិកុតុ ដែលជាព្រះនៅក្នុងទេវកថារបស់ជប៉ុន និងជាប្រភពដើមនៃឈ្មោះខេត្តអិហ៊ីមុ។ ត្ស៊ឹបាគិម៉ាត្ស៊ឺរិ (ពិធីបុណ្យផ្កាត្ស៊ឹបាគិ) ដែលត្រូវបានប្រារព្ធឡើងនៅអំឡុងខែកុម្ភៈជារៀងរាល់ឆ្នាំ គឺបុណ្យប្រពៃណីមួយរបស់អ្នកស្រុកទន្ទឹងរង់ចាំការមកដល់និទាឃរដូវ។ លើសពីនេះទៀត ប្រសិនបើអ្នកជិះរថភ្លើងជាងមួយម៉ោងចេញទៅ

ក្រៅក្រុង អ្នកនឹងទៅដល់ស្ថានីយ៍ស៊ិម៉ុណាដា ជាមួយនឹងទិដ្ឋភាពនៃមហាសមុទ្រដ៏អស្ចារ្យ និង"អ៊ុឈិកុហ្សា" ដែលជារោងមហោស្រពដែលបានសាងសង់ប្រហែលកាលពី១០០ឆ្នាំមុន។

ម៉ាត្ស៊ុយ៉ាម៉ា ក៏មានអាហារពិសេសៗជាច្រើននៅក្នុងស្រុកផងដែរ។ តំបន់នេះគឺជាកន្លែងផលិតផ្លែក្រូចជប៉ុន(មិកាន)ដ៏ធំបំផុតមួយនៅក្នុងប្រទេសជប៉ុន ហើយម៉ាត្ស៊ុយ៉ាម៉ា ក៏បានផលិតនូវទឹកក្រូចច្របាច់ថ្មីៗពីផ្លែក្រូចក្នុងតំបន់នេះ ដែលត្រូវបានគេដឹងថារសជាតិមានតុល្យភាពជូរផ្អែមយ៉ាងល្អឥតខ្ចោះ។ ម្ហូបពិសេសមួយទៀតរបស់ម៉ាត្ស៊ុយ៉ាម៉ា គឺ "តៃម៉ិស៊ិ" ជាបាយចំហុយជាមួយត្រីតៃ ដែលបានមកពីក្នុងសមុទ្រសិតុណៃកៃ។ ម្យ៉ាងទៀតអ្នកប្រហែលជាចង់ទទួលទាន"ណាបិយ៉ាគិ អ៊ុដុន(ស៊ុបឆ្នាំងដីមីអ៊ុដុន)" ដែលជាស៊ុបមីអ៊ុដុងក្តៅៗដោយប្រើទឹកជាស៊ិផ្អែម(អាម៉ៃដាស៊ិ)ដ៏ឈ្ងុយឆ្ងាញ់។

សូមរីករាយនឹងទេសភាព និងរសជាតិពេលដើរកំសាន្តជុំវិញទីក្រុង ហើយរំលឹកពេលវេលាដែលមិនអាចបំភ្លេចបានដោយការសរសេរកំណាព្យហៃគឹ សម្រាប់ការចងចាំពិសេសបន្ថែមនៃការធ្វើដំណើររបស់អ្នកទៅកាន់ម៉ាត្ស៊ុយ៉ាម៉ា។

*ផែនទីតំបន់ម៉ាត្ស៊ុយ៉ាម៉ា (សូមមើលរូប)*

*១. ដូហ្គុអុនសេនហុនកាន*

*២. ប្រាសាទម៉ាត្ស៊ុយ៉ាម៉ា*

*៣. ព្រះវិហារអ៊ីយ៉ូហ្ស៊ឹ ហ៊ីកុ ណុ មិកុតុ*

*៤. ភោជនីយដ្ឋានកុតុរិ*

៥. 10FACTORY

*៦. ភោជនីយដ្ឋានអាកា*

*. មធ្យោបាយធ្វើដំណើរ៖ ពីព្រលានយន្តហោះហាណេដា ទៅកាន់ព្រលានយន្តហោះម៉ាត្ស៊ុយ៉ាម៉ា គឺប្រហែល ១ម៉ោងកន្លះ តាមយន្តហោះ។*

*ពីព្រលានយន្តហោះម៉ាត្ស៊ុយ៉ាម៉ា ទៅកាន់ស្ថានីយ៍ម៉ាត្ស៊ុយ៉ាម៉ា គឺប្រហែល១៥នាទីដោយរថយន្តក្រុង។*

*. ទំនាក់ទំនងព័ត៌មាន សូមចូលទៅកាន់គេហទំព័រទេចរណ៍ផ្លូវការរបស់ម៉ាត្ស៊ុយ៉ាម៉ា*

https://en.matsuyama-sightseeing.com/

## ទំព័រទី២៤៖ **វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ ㉔**

*រូបភាពដោយ ហុនហ្គុ ជិន*

**ប៊ិចកែវ** មានដើមកំណើតនៅប្រទេសជប៉ុន! ស្រស់ស្អាត និងងាយស្រួលប្រើ!

សរសេរកំណត់ហេតុប្រចាំថ្ងៃ ឬសំបុត្រទៅមិត្តភក្តិដោយប្រើប៊ិច និងទឹកខ្មៅដែលអ្នកចូលចិត្ត។ សព្វថ្ងៃនេះ ការសរសេរអក្សរនៅលើឧបករណ៍ឌីជីថលបានក្លាយជារឿងធម្មតា ហើយមនុស្សកាន់តែច្រើនកំពុងស្វែងរកភាពរីករាយក្នុងការសរសេរដោយដៃ។ ប៊ិចកែវ គឺជាការបន្ថែមពណ៌ទៅក្នុងពេលវេលាពិសេសរបស់អ្នក ។

ប៊ិចនេះមិនត្រឹមតែស្រស់ស្អាតប៉ុណ្ណោះទេ ថែមទាំងអាចប្រើប្រាស់បានយ៉ាងងាយស្រួលថែមទៀតផង។ អ្នកអាចសរសេរអក្សរបានយ៉ាងរលូនដោយមិនចាំបាច់ខំប្រឹង និងរក្សាទឹកប៊ិចបានល្អ។ អ្នកអាចផ្លាស់ប្តូរទឹកប៊ិចបានយ៉ាងងាយស្រួលដោយគ្រាន់តែលាងជម្រះជាមួយនឹងទឹក ហើយជូតឱ្យស្ងួត ដូច្នេះអ្នកអាចរីករាយជាមួយនឹងពណ៌ផ្សេងៗទៅតាមអារម្មណ៍ និងគោលបំណងរបស់អ្នក។ ភាពរីករាយពិតប្រាកដមួយនៃប៊ិចកែវនេះ គឺអ្នកអាចមើលឃើញទឹកប៊ិចនៅចុងប៊ិច ដែលមានពណ៌យ៉ាងរស់រវើក។

ប៊ិចកែវត្រូវបានគេនិយាយថា ត្រូវបានបង្កើតឡើងដោយសិប្បកររកណ្តឹងខ្យល់នៅដើមសតវត្សរ៍ទី២០។ ដំបូងឡើយមានតែសំបកធ្វើពីកែវប៉ុណ្ណោះ ប៉ុន្តែទីបំផុតរាងកាយប៊ិចទាំងមូលក៏ធ្វើពីកែវទាំងអស់ ហើយវាបានក្លាយទៅជាឧបករណ៍សរសេរដ៏ស្រស់ស្អាតដូចការងារសិល្បៈមួយ។ ប៊ិចនីមួយៗត្រូវបានសិប្បករធ្វើដោយដៃ ដូច្នេះហើយមិនមានរាង ឬពណ៌ដូចគ្នាទេ។ ប៊ិចកែវមួយអ្នកអាចជួបតែម្តងក្នុងមួយជីវិតទេ។ ស្វែងរកប៊ិចកែវពិសេសដែលទាក់ទាញភ្នែករបស់អ្នក ហើយរីករាយក្នុងការកាន់សរសេរប៊ិចមួយដើមនោះ។

*ផ្នែកឆ្វេងខាងក្រោម: ចំនួនចង្អូរនៅចុងប៊ិចមានពី៨ ទៅ១២ចង្អូរ។*

*ផ្នែកស្តាំខាងលើ: នៅពេលជ្រលក់ចុងប៊ិចទៅក្នុងទឹកប៊ិច ពេលនោះទឹកប៊ិចនឹងបឺតចូលទៅក្នុងចង្អូរចុងប៊ិច។*

*ផ្នែកស្តាំខាងក្រោម: ជ្រលក់ទឹកប៊ិចម្តង អ្នកអាចសរសេរកាតប៉ុស្តាល់បានមួយសន្លឹក។*

*ទស្សនាវដ្តី "និប៉ុនិកា" លេខ៣៣*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/
*គេហទំព័រដែលផ្តល់ព័ត៌មានអំពីជប៉ុន* https://web-japan.org/